គ.ជ.អ.ប
NCDD

# ហេតុដូចម្តេចបានជាត្រូវការទីប្រឹក្សាកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ?



## មាតិកា

1. រំលឹកដោយសង្ខេបអំពីកម្មវិធីជាតិ
   - គោលដៅនិងគោលបំណងនៃកម្មវិធីជាតិ
   - សមិទ្ធផលនៃកំណែទម្រង់
   - លទ្ធផលរំពឹងទុកក្នុងការបំពេញមុខងាររបស់SNA
   - ការរៀបចំឡើងវិញនូវប្រព័ន្ធអភិបាលកិច្ចនិងរដ្ឋបាល
   - មុខងារជាភារកិច្ចនិងការប្រគល់មុខងារឡើងវិញ
   - បញ្ហាប្រឈមនានា
2. តួនាទីនិងភារកិច្ចរបស់ទីប្រឹក្សាកម្មវិធីជាតិថ្នាក់ស្រុក
   - ការកសាងសមត្ថភាពបុគ្គលិក
   - ការកសាងសមត្ថភាពស្ថាប័ន
   - គាំទ្រដល់ការិយាល័យផែនការនិងគាំទ្រឃុំសង្កាត់
   - កិច្ចការផ្សេងទៀត
   - ខ្សែគណនេយ្យភាពនិងទំនាក់ទំនង

## គោលបំណងនៃកម្មវិធីជាតិ

ដើម្បី**បង្កើតប្រព័ន្ធគ្រប់គ្រង**នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផ្អែកតាមគោលការណ៍នៃការ**ចូលរួម**ពីប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យ ធានាដល់ការអនុវត្តប្រកបដោយ**តម្លាភាព**និង**គណនេយ្យភាព** សំដៅ**លើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន** និងការផ្តល់**សេវាសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធ** ដើម្បី**ឆ្លើយតបទៅនឹងតម្រូវការ**របស់ប្រជាពលរដ្ឋ នាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចព្រមទាំង**រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ**នៅតាមមូលដ្ឋាននីមួយៗ។



## ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានលក្ខណៈ

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់និងការចូលរួម
- ការឆ្លើយតបនិងគណនេយ្យភាព
- លើកកំពស់គុណភាពជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាពនិងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយនិងរំលោភអំណាច

## សមិទ្ធផលនៃកំណែទម្រង់ដែលសម្រេចបានកន្លងមក

- មិនជាបញ្ហាថ្មីសម្រាប់កម្ពុជា ដោយកំណែទម្រង់ចាប់ផ្តើមតាំងពីឆ្នាំ២០០២
- ច្បាប់ស្តីពីការគ្រប់.ឃុំសង្កាត់២០០១ (បោះឆ្នោតលើកទី១ កុម្ភៈឆ្នាំ២០០២ ទី២ មេសា ឆ្នាំ២០០៧ និងទី៣ មិថុនា ឆ្នាំ២០១២)
- OL II ខែឧសភា ឆ្នាំ២០០៨ បោះឆ្នោតលើកទី១ ខែឧសភា ឆ្នាំ២០០៩
- សមិទ្ធផលថ្នាក់ឃុំសង្កាត់: ភាពជាតំណាងស្របច្បាប់ នីតិវិធីកសាងផែនការ និងថវិកា រួមចំណែកកសាងសន្តិភាព កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងកំណើនសេដ្ឋកិច្ច នឹងពង្រឹងរាជរដ្ឋាភិបាលរឹងមាំនិងមានការគាំទ្រកាន់តែច្រើន
- សមិទ្ធផលថ្នាក់ក្រុងស្រុក: គម្រោងសាកល្បង និងយន្តការគាំទ្រក្លាយជាមូលដ្ឋានក្នុងដំណើរការកំណែទម្រង់ រចនាសម្ព័ន្ធរដ្ឋបាល និងថវិកាត្រូវបានបង្កើត
- ការចូលរួមចំណែកក្នុងដំណើរការកំណែទម្រង់របស់ក្រសួង ស្ថាប័នតាមរយៈការផ្ទេរមុខងារ



## លទ្ធផលរំពឹងទុកក្នុងការបំពេញមុខងាររបស់SNA

- ក្រុងស្រុកទាំងអស់នឹងមានបុគ្គលិក(ដែលមានសមត្ថភាព)គ្រប់គ្រាន់សម្រាប់ទ្រទ្រង់កិច្ចដំណើរការរដ្ឋបាលទាំងនេះផងនិងគាំទ្រដល់ឃុំសង្កាត់ផង
- មូលនិធិអន្តរានុសិទ្ធនិងយន្តការនានាក្នុងការផ្តល់មូលនិធិសម្រាប់គម្រោងនឹងត្រូវរៀបចំសម្រាប់ថ្នាក់ក្រោមជាតិ
- ក្រុមប្រឹក្សានានានឹងត្រូវបានចូលរួមផ្តល់យោបល់ដោយប្រជាជន។ គេនឹងប្រើប្រាស់ពត៌មានស្តីពីការកសាងផែនការដើម្បីធ្វើការសម្រេចចិត្តនិងផ្តល់សេវាទាំងឡាយតាមរយៈទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុនិងលទ្ធកម្ម
- ប្រព័ន្ធរដ្ឋបាលនិងហិរញ្ញវត្ថុរបស់SNA ត្រូវបានអភិវឌ្ឍ
- SNA នឹងផ្តល់សេវាថ្មីៗនិងមានលក្ខណៈប្រសើរជាងមុនដល់ប្រជាពលរដ្ឋ និងអាទិភាពរបស់មូលដ្ឋានជាងមុន
- រដ្ឋបាលថ្នាក់ខេត្តនឹងត្រូវបានសម្របសម្រួលឲ្យទទួលតួនាទីថ្មីៗរបស់ខ្លួនក្នុងការកសាងសមត្ថភាពនឹងគាំទ្ររដ្ឋបាលមូលដ្ឋានដោយមិនប៉ះពាល់ដល់ស្វ័យភាពរបស់ក្រុង ស្រុក ឃុំ សង្កាត់

## ការរៀបចំឡើងវិញនូវប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ

- ភាពខុសគ្នារវាងខេត្តនិងមូលដ្ឋាន: កម្ពុជាជារដ្ឋទោល ដែលនៅក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- កំណែទម្រង់ដែលកំណត់ដោយច្បាប់មានបំណងលុបបំបាត់ប្រព័ន្ធគ្រប់គ្រងតាមឋានានុក្រម។
- ក្នុងប្រព័ន្ធចាស់ ស្រុកជាអង្គភាពរដ្ឋបាលនិងជាអង្គភាពស្ថិតក្នុងដែនដីរបស់ខេត្ត
- ប្រព័ន្ធថ្មី ក្រុងនិងស្រុកមានក្រុមប្រឹក្សាដែលមានស្វ័យភាព អណត្តិ និងមូលនិធិផ្ទាល់។



## ការរៀបចំឡើងវិញ... “ត”

- ដូចនេះតួនាទីរដ្ឋបាលខេត្តពាក់ព័ន្ធក្រុងស្រុកគឺ: ផ្តល់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការរៀបចំផែនការនឹងការសម្រេចចិត្តនៅមូលដ្ឋាន។ ដាក់ឲ្យដំណើរការនិងរក្សាយន្តការសមស្របសម្រាប់គ្រប់គ្រងធនធានមនុស្សនិងហិរញ្ញវត្ថុនិងការត្រតពិនិត្យមើល។ កសាងសមត្ថភាពនៅមូលដ្ឋានដើម្បីបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។
- គោលដៅជាយុទ្ធសាស្ត្រនៃដំណើរការកំណែទម្រង់វិម.នៅកម្ពុជាគឺ ការផ្ទេរការទទួលខុសត្រូវក្នុងការផ្តល់សេវាជាបណ្តើរៗឲ្យក្រុង ស្រុក ឃុំ សង្កាត់ និងការពង្រឹងសមត្ថភាពថ្នាក់ជាតិក្នុងការកសាងផែនការយុទ្ធសាស្ត្រ និងការវិនិយោគក៏ដូចជាគាំទ្រប្រកប ដោយប្រសិទ្ធភាពនិងការត្រួតពិនិត្យមើលការបំពេញការងាររបស់ក្រុងស្រុកឃុំសង្កាត់

## មុខងារជាភារកិច្ចនិងការប្រគល់មុខងារឡើងវិញ

- OL តម្រូវឱ្យSNA បំពេញមុខងារលើសពីអណត្តិទូទៅរបស់ខ្លួន និងត្រូវបានប្រគល់មុខងារក្នុងការផ្តល់សេវាជាក់លាក់ ដែលបច្ចុប្បន្នមុខងារទាំងនេះបំពេញដោយរដ្ឋបាលថ្នាក់ជាតិ។
- មានន័យថាក្រុងស្រុកឃុំសង្កាត់នឹងត្រូវបានធ្វើប្រតិភូកម្ម ឱ្យបំពេញមុខងារក្នុងនាមជាអង្គភាពមានស្វ័យភាពក្នុងការអនុវត្តកម្មវិធីនានារបស់ក្រសួង ស្ថាប័ន
- ក្រុងស្រុកឃុំសង្កាត់នឹងទទួលខុសត្រូវទាំងស្រុងលើការផ្តល់សេវាដែលដំបូងទទួលមូលនិធិនិងត្រួតពិនិត្យពីក្រសួង
- ក្រុងស្រុកឃុំសង្កាត់ត្រូវកែសម្រួលដំណើរការនិងស្តង់ដារនៃការ ផ្តល់សេវា ស្របតាមស្ថានភាពមូលដ្ឋានដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងពង្រឹងសមត្ថភាព



## ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីគាំទនឹងភាពចាំបាច់នៃកំណែទម្រង់

*"កម្ពុជាគ្មានជម្រើសណាល្អប្រសើរ ក្រៅតែពីការធ្វើកំណែទម្រង់ទេ នៅក្នុងឱកាសដែលប្រទេសជាតិយើងកំពុងតែទទួលផលចំណេញពីសន្តិភាព និងស្ថិរភាពដែលយើងខិតខំកសាង និងការពារបាន។ រដ្ឋបាលសាធារណៈសព្វថ្ងៃត្រូវធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅថែមទៀត ដើម្បីប្រែក្លាយខ្លួនឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធិភាព និងជាដៃគូអភិវឌ្ឍន៍ដែលអាចទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង"*

## បញ្ហាប្រឈមនានាដែលជំរុញឲ្យមានកំណែទម្រង់

- បញ្ហាប្រឈមទាក់ទងនឹងការផ្តល់សេវាសាធារណៈដូចជាគុណភាព ប្រសិទ្ធភាពនៅមានកម្រិតទាប និងមិនទាន់អាចឆ្លើយតបនឹងតម្រូវការចាំបាច់
- បញ្ហាប្រឈមទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋាន:

1. ការបំពេញការងាររដ្ឋបាលប្រកបដោយគណនេយ្យភាពនិងការឆ្លើយតបរបស់ថ្នាក់ក្រោមជាតិចំពោះតម្រូវការនៅមូលដ្ឋាននៅមានភាពទន់ខ្សោយ
2. ការផ្តល់សេវាតភាធារណៈ: លិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងទីផ្សារ និងទ្រព្យសម្បត្តិសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានភាពមិនច្បាស់លាស់រវាងប្រព័ន្ធគ្រប់.តាមបែបមជ្ឈការ វិម. និងវិសហម.
3. ភាពមិនចុះសម្រុងគ្នានៃកម្មវិធីនានាដែលទទួលហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ
4. ក្នុងដំណើរការអភិ.តាមបែបប្រជា. យន្តការគណនេយ្យភាពមួយចំនួនសម្រាប់ការជជែក ពិភាក្សា ការតស៊ូមតិ និងការទិតៀនទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាលដំណើរការតែនៅក្នុងប្រព័ន្ធបោះឆ្នោតនិងប្រព័ន្ធនយោបាយប៉ុណ្ណោះ។



## បញ្ហាប្រឈមផ្នែកធនធានមនុស្ស

- វិធីសាស្ត្រអភិវឌ្ឍសមត្ថភាពSNA ត្រូវធ្វើឡើងផ្អែកលើសមត្ថភាពដែលមានស្រាប់
- សមត្ថភាពមានស្រាប់សំដៅលើបុគ្គលិកដែលបំពេញការងារជាមួយគប្រ និងមួយចំនួនទៀតដែលគាំទ្រដល់សកម្មភាពឃុំសង្កាត់ ដែលភាគច្រើនមកពីមន្ទីរផ្សេង
- ក្រុងស្រុកជាថ្នាក់រដ្ឋបាលជួរមុខថ្មីមួយ ប៉ុន្តែសមត្ថភាពនៅមានកំរិតដោយសារ៖ ក) ក្រុមប្រឹក្សានានាត្រូវបានជាប់ឆ្នោត ប៉ុន្តែពុំទាន់មានដំណើរការរៀបចំស្ថាប័ន ដើម្បីធានាដល់ការរៀបចំគោលនយោបាយនិងការចូលរួម។ ខ) ផ្នែកប្រតិបត្តិបច្ចុប្បន្នមានបុគ្គលិកតិចតួច និងសមត្ថភាពមានកំរិត និងពុំទាន់មានប្រភពធនធាននិងប្រព័ន្ធគាំទ្រ។
- ផ្អែកតាមតម្រូវការនៃកំណែទម្រង់នេះ សមត្ថភាពធនធានមនុស្សគឺជាបញ្ហាប្រឈមមួយដើម្បីឆ្លើយតបនឹងមហិច្ឆិតារបស់RGC និងការរំពឹងទុករបស់ប្រជាពលរដ្ឋ
- ការខ្វះខាតធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ មិនមែនបណ្តាលមកតែពីសមត្ថភាព ប៉ុន្តែមកពីកត្តាផ្សេងទៀតដូចជាប្រព័ន្ធស្ថាប័នខ្សោយ ខ្វះថវិកា។
- ធនធានដែលមានសមត្ថភាព បានបំពេញការងារក្រៅប្រព័ន្ធរដ្ឋាភិបាល។

## ភារកិច្ចជាក់លាក់របស់ទីប្រឹក្សាក្រុង ស្រុក ខណ្ឌ

ទីប្រឹក្សាកម្មវិធីជាតិថ្នាក់ក្រុង ស្រុក ខណ្ឌនឹងពង្រឹងសមត្ថភាពរដ្ឋបាលដើម្បីគ្រប់គ្រងមុខងារនិងការទទួលខុសត្រូវស្របតាមគោលនយោបាយជាតិ លិខិតបទដ្ឋាននិងសេចក្តីណែនាំនានានៅក្នុង ផអ៣ ដោយផ្តោតលើ:

- ការកសាងសមត្ថភាពបុគ្គលិក
- ការកសាងសមត្ថភាពស្ថាប័ន
- ជួយដល់ការិយាល័យផែនការនិងគាំទ្រឃុំសង្កាត់
- កិច្ចការផ្សេងទៀត



## ការអភិវឌ្ឍសមត្ថភាព

- ជាសមាសធាតុស្នូលដ៏សំខាន់នៃកម្មវិធីជាតិ ពីព្រោះធានាដល់ការបង្កើត ជំរុញនិងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ។
- ជាបុរេលក្ខខណ្ឌក្នុងការផ្តល់លទ្ធភាពដើម្បីបំពេញការងារ
- ដើម្បីដោះស្រាយតម្រូវការចាំបាច់និងបន្ទាន់របស់បុគ្គលិកនិងស្ថាប័ន

## ការកសាងសមត្ថភាពបុគ្គលិក

**ការអភិវឌ្ឍសមត្ថភាពបុគ្គលសំដៅដល់ការអភិវឌ្ឍភាពក្លាហានរបស់បុគ្គលិក ជាពិសេសចំណេះដឹង ទេព្យកោសល្យ អាកប្បកិរិយា បទពិសោធន៍ សម្រាប់បុគ្គលិកឬអ្នកដឹកនាំដើម្បីបង្កើនប្រសិទ្ធភាពការងារដោយមានការទទួលខុសត្រូវ។ ការងារនេះផ្តោតលើ៖**

- កិច្ចការរដ្ឋបាលៈ ធានាការយល់ដឹងអំពីប្រព័ន្ធគ្រប់គ្រង នីតិវិធី ទម្រង់ការគ្រប់គ្រងបុគ្គ. ទ្រព្យសម្បត្តិ ចុះបញ្ជីអត្រានុកូលដ្ឋាន ទុកដាក់ឯកសារ
- ហិរញ្ញវត្ថុៈ ធានាថាយល់ពីគោលការណ៍ហិរ.មានសមត្ថភាពរៀបចំថវិកា ការងារគណនេយ្យ ជម្រះបញ្ជី របាយការណ៍
- លទ្ធកម្មៈ ធានាថាយល់ពីគោលការណ៍ និងដំណើរការលទ្ធកម្ម ប្រកបដោយតម្លាភាព
- ការរៀបចំរបាយការណ៍ៈ ធានាដល់ការរៀបចំរបាយការណ៍ប្រកបដោយគុណភាពនិងទាន់ពេល



## ការកសាងសមត្ថភាពបុគ្គលិក “ត”

- ការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគៈ ធានាថាយល់ដឹងពីនីតិវិធី ដំណើរការ និងទម្រង់នៃការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ប្រកបដោយគុណភាព និង អនុម័តទាន់ពេល។ ធានាការយល់ដឹងអំពីគោលការណ៍និងនីតិវិធីនៃការរៀបចំនិងការចុះកិច្ចសន្យា ការអនុវត្តនិងត្រួតពិនិត្យ។
- ទំនាក់ទំនងៈ ធានាការយល់ដឹងពីគោលការណ៍នៃទំនាក់ទំនងនិងការផ្សព្វផ្សាយពត៌មាន ការរៀបចំវេទិកាសាធារណៈ និងទំនាក់ទំនងជាមួយប្រជាពលរដ្ឋ
- ការកសាងសមត្ថភាពៈ ជួយគាំទ្រនិងចូលរួមរាល់សកម្មភាពអភិវឌ្ឍន៍ស្របតាមគោលការណ៍ណែនាំនិងវិធីសាស្ត្រ។ ធានាថាផែនការសកម្មភាពត្រូវបានរៀបចំ ព្រមទាំងមានរបាយការណ៍ត្រឹមត្រូវ។

## ការកសាងសមត្ថភាពបុគ្គលិក "ត"

- ការងារយ៉េនឌ័រ: ធានាថាយុទ្ធសាស្ត្រនៃការបញ្ជ្រាបយេនឌ័រ (ផ្តល់សិទ្ធិអំណាចនិងបង្កើនភាពក្លាហាន) ត្រូវបានអនុវត្ត។ ពង្រឹងសមត្ថភាព គ.ស.ន.ក និងជំរុញទំនាក់ទំនងជាមួយ គ.ក.ន.ក
- ការអភិរក្សធនធានធម្មជាតិនិងបរិស្ថាន នឹងបំរែបំរួលអាកាសធាតុ (Climate Change)
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ: តាមការស្នើសុំ និងដោយមានការសម្របសម្រួលពីនាយករដ្ឋបាល់និងអ្នកសម្របសម្រួលក្រុមប្រឹក្សា ផ្តល់នូវពត៏មានអំពីអណត្តិ តួនាទីនិងភារកិច្ច និងទំនាក់ទំនងរវាងគណៈអភិបាលនិងក្រុមប្រឹក្សា និងរវាងក្រុមប្រឹក្សាប្រភេទផ្សេងគ្នា។



## ការកសាងសមត្ថភាពស្ថាប័នជាក់លាក់

ការអភិវឌ្ឍសមត្ថភាពស្ថាប័ន សំដៅដល់ការអភិវឌ្ឍភាពរបស់ស្ថាប័នដើម្បីឆ្លើយតបទៅនឹងគោលបំណងនិងអណត្តិ ពោលគឺប្រព័ន្ធស្ថាប័ន យុទ្ធសាស្ត្រ ភាពជាអ្នកដឹកនាំ ការប្រាស្រ័យទាក់ទង និងធនធានដែលអាចឲ្យSNA បំពេញមុខងារស្ថាប័នប្រកបដោយប្រសិទ្ធិភាព។ ការងារនេះផ្តោតលើ៖

- ការតម្រង់ទិស: ធានាឲ្យមានការយល់ដឹងអំពីស្ថាប័ន រចនាសម្ព័ន្ធភាពទាក់ទងទៅវិញទៅមក បង្កើតភាពទុកចិត្ត
- ការវាយតម្លៃស្ថាប័ន: ពិនិត្យលើចំណុចខ្លាំង/ខ្សោយរបស់ស្ថាប័នដោយប្រើប្រាស់ឧបករណ៍វាយតម្លៃជាប្រព័ន្ធនិងមានការចូលរួម

## ការកសាងសមត្ថភាពស្ថាប័ន "ឥ"

- រៀបចំផែនការអន្តរាគមន៍អភិវឌ្ឍស្ថាប័នៈ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ ដោយកំណត់អំពីគោលបំណង សូចនាករណ៍ អ្នកចូលរួម និងពេលវេលាត្រឹមត្រូវ ដែលផែនការនេះត្រូវអនុវត្តនាពេលបន្ទាប់តាមលទ្ធភាពដែលមាន។
- រៀបចំវាយតម្លៃលទ្ធផលៈ វាយតម្លៃលើសមិទ្ធិផលនិងផលប៉ះពាល់ដោយប្រៀបធៀបជាមួយគោលបំណងនៃផែនការនិងសូចនាករណ៍បានលើក។



## ការគាំទ្រដល់ការិយាល័យផែនការនិងគាំទ្រឃុំសង្កាត់

- គាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំនិងការរៀបចំកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំសង្កាត់
- ជំរុញការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ និងធានាថាអនុលោមតាមសេចក្តីណែនាំនៃការអនុវត្តគម្រោង ប្រកបដោយគណនេយ្យភាព និងតម្លាភាព។
- ផ្តល់ការណែនាំក្នុងការរៀបចំប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងការរៀបចំកំណត់ហេតុប្រកបដោយខ្លឹមសារ
- ផ្តល់ការណែនាំក្នុងការរៀបចំប្រជុំរបស់ គ.ក.ន.ក និង គ.ស.ន.ក
- ផ្តល់ការណែនាំក្នុងការរៀបទុកដាក់ឯកសារ

# កិច្ចការផ្សេងទៀត




គាំទ្រដល់រដ្ឋបាលក្រុងស្រុកទាំងមូលក្នុងការរៀបចំ:

- ដំណើរការកិច្ចប្រជុំ: របៀបវារៈ អ្នកចូលរួម ឯកសារចែកចាយ ឬរបាយការណ៍សម្រាប់ការប្រជុំ និងកំណត់ហេតុ...
- ផែនការ/របាយការណ៍អនុវត្តការងារ ប្រចាំខែ ត្រីមាស ឆ្នាំ
- ការសម្របសម្រួលក្នុងការប្រមូលនិង បញ្ចូលទិន្នន័យ CD Baseline, DIS, and Social Service Indicators????
- ការងារផ្សេងៗទៀត ដូចជា...





# គាំទ្រការប្រមូលនិងបញ្ចូលទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌ

| DMK Advisors | DITAs |
|---|---|
| • ជាសមាជិកក្រុមការងារ<br>• សម្របសម្រួលក្នុងការកំណត់ពេលវេលាប្រមូលទិន្នន័យនិងការបំពេញទម្រង់នានា<br>• ពិនិត្យបញ្ជីសំណួរដែលបានបំពេញ ធានានូវពត៌មានគ្រប់គ្រាន់<br>• ផ្តល់ការគាំទ្រដល់DITAs ក្នុងការបញ្ចូលទិន្នន័យ<br>• ជួយក្រុមការងារក្នុងការរៀបចំរបាយការណ៍ | • ធានាការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទិន្នន័យ ដោយអនុវត្តតាមគោលការណ៍ណែនាំ និងធានាភាពត្រឹមត្រូវ |
| ភាពញឹកញាប់: នាពេលចាប់ផ្តើម និងចុងបញ្ចប់នៃ ផអពដំបូង។ | |

# ការគាំទ្រដល់ការប្រមូលនិងបញ្ចូលសូចនាករសេវាសង្គម

| DMK Advisors | DITAs |
| --- | --- |
| • មុនពេលប្រមូលពត៌មាន: ទទួលការបណ្តុះសម្របសម្រួលនិងណែនាំដល់មន្ត្រីផែនការ និងគាំទ្រឃុំសង្កាត់ មន្ត្រីសេវាសង្គម និង DITA<br>• ពេលប្រមូល: ជួយមន្ត្រីសេវាសង្គមណែនាំដល់ឃុំសង្កាត់នឹងស្មៀន ពិនិត្យលើការចែកទម្រង់ ពិនិត្យទម្រង់ដែលបានបំពេញ និងប្រគល់ទម្រង់ដល់ DITA<br>• ក្រោយពេលប្រមូល: បញ្ចូលទិន្នន័យចំពោះក្រុងស្រុកខណ្ឌមិនមានDITA | • ធានាការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទិន្នន័យ ដោយអនុវត្តតាមគោលការណ៍ណែនាំ និងធានាភាពត្រឹមត្រូវ |
| • ភាពញឹកញាប់: ប្រចាំខែ ឬ ត្រីមាស ???? | |



# គាំទ្រការប្រមូលនិងបញ្ចូលទិន្នន័យប្រព័ន្ធពត៌មានក្រុង ស្រុក ខណ្ឌ

| អភិបាលរង/ នាយក រដ្ឋបាល | ប្រជុំដឹកនាំក្នុងការ ប្រមូលទិន្នន័យ ពិនិត្យលើទិន្នន័យដែលប្រមូលបាន និងដាក់ជូនអភិបាលចុះហត្ថលេខា |
| --- | --- |
| DITA | • ចែកចាយទម្រង់ ធានាការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទិន្នន័យ ដោយអនុវត្តតាមគោលការណ៍ណែនាំ និងធានាភាពត្រឹមត្រូវ<br>• បូកសរុបបញ្ចូលគ្នាជាFileតែមួយនិងផ្ញើទៅPITA បន្ទាប់ពីអភិបាលចុះហត្ថលេខារួច |
| PITA | • គាំទ្រដល់DITA លើដំណើរការប្រមូលនិងបញ្ចូលទិន្នន័យ<br>• ត្រួតពិនិត្យនិងបញ្ចូលពត៌មានក្នុងប្រព័ន្ធទិន្នន័យ<br>• ផ្ញើប្រព័ន្ធទិន្នន័យទៅភ្នំពេញ |
| **DMK Advisor** | • សម្របសម្រួលក្នុងការប្រជុំ ពិនិត្យកាលបរិច្ឆេទនៃការប្រមូល គុណភាពពត៌មានដែលផ្តល់/ភាពខ្វះចន្លោះ |
| ភាពញឹកញាប់: ប្រចាំឆ្នាំ | |

## ខ្សែគណនេយ្យភាព និងទំនាក់ទំនង

- នៅថ្នាក់រាជធានី ខេត្ត DMKAs ស្ថិតនៅក្រោមការគ្រប់.ផ្ទាល់របស់នាយរដ្ឋបាលឬសមាជិកអចិន្ត្រៃយ៍ ផអព និងក្រោមការគ្រប់.និងគាំទ្របច្ចេកទេសរបស់ PPMA។
- DMKAs ត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាល ក្រុង ស្រុក ខណ្ឌ និងត្រូវរាយការណ៍ជាប្រចាំអំពីការអនុវត្តកម្មវិធី
- ស្នាដៃនៃការបំពេញភារកិច្ចរបស់ទីប្រឹក្សា ត្រូវបានវិនិច្ឆ័យលើការប្រកាន់ខ្ជាប់នូវតម្លៃនិងក្រមសីលធម៌របស់បុគ្គលិក សមត្ថភាពជំនាញ និងសមត្ថភាពក្នុងការវិភាគ គុណភាពនិងល្បឿននៃការបំពេញការងារ និងកម្រិតនិងគុណភាពនៃការផ្ទេរចំណេះដឹងនិងជំនាញ
- ក្នុងករណីចាំបាច់ស្វែងរកការគាំទ្រពីទីប្រឹក្សាកម្មវិធីក្នុងខេត្ត ថ្នាក់ជាតិ និងក្រុមការងារកសាងសមត្ថភាព



# សូមអរគុណ



# Q&A